# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ៧១ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការភាសាវិទ្យាខ្មែរ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

### ស ម្រេ ច

**ប្រការ ១:** ត្រូវបានបង្កើតគណៈកម្មការភាសាវិទ្យាខ្មែរ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **សូ ម៉ុយឃៀង** | សមាជិកគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ (គ.ប.ស) | ប្រធាន |
| ២-ឯកឧត្តម **ចំនួ សំណាង** | សមាជិក គ.ប.ស | អនុប្រធាន |
| ៣-ឯកឧត្តម **ឆយ អូន** | សមាជិក គ.ប.ស | សមាជិក |
| ៤- ឯកឧត្តម **អ៊ុច ច័ន** | សមាជិក គ.ប.ស | សមាជិក |

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | ម៉ុញ សាវី | អនុប្រធានអចិន្ត្រៃយ៍នៃលេខាធិការដ្ឋាន គ.ប.ស | សមាជិក |
| ៦-ឯកឧត្តម | ស៊ឹង ផុស | សមាជិក គ.ប.ស | សមាជិក |
| ៧-លោក | ថាច់ សែម | សមាជិក គ.ប.ស | សមាជិក |
| ៨-លោក | ម៉ុម ម៉ុន | សមាជិកលេខាធិការដ្ឋាន គ.ប.ស | សមាជិក |
| ៩-លោក | ឃឿង ទីរបុត្រ | សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០-លោក | ទូច គីមស្រ៊ាង | មន្ត្រីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ | សមាជិក ។ |

**ប្រការ ២:** គណៈកម្មការភាសាវិទ្យាខ្មែរ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣:** គណៈកម្មការភាសាវិទ្យាខ្មែរ ទទួលពិនិត្យពាក្យ ឃ្លា ប្រយោគ និងអក្ខរាវិរុទ្ធ នៃឯកសារទាំងឡាយ ដែលត្រូវដាក់ឆ្លងកិច្ចប្រជុំរវាងក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងក្រសួងសាមីពាក់ព័ន្ធ កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី ព្រមទាំងឯកសារផ្សេងៗទៀត ដែលរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៤:** ប្រធានគណៈកម្មការភាសាវិទ្យាខ្មែរ ត្រូវចូលរួម ឬចាត់តាំងតំណាងចូលរួមក្នុងកិច្ចប្រជុំដូចមានចែងក្នុងប្រការ ៣ ដើម្បីជូនយោបល់ភ្លាម ក្នុងករណីមានការខ្វែងមតិគ្នាលើការប្រើប្រាស់ពាក្យ ឃ្លា ប្រយោគ និងអក្ខរាវិរុទ្ធ ។

**ប្រការ ៥:** ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ប្រធានគណៈកម្មការភាសាវិទ្យាខ្មែរ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ១០ ឆ្នាំ ២០០៨

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

***កន្លែងទទួល :***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ